COUNT US IN 2020

There's Power In Being Counted

ASIAN AMERICANS ADVANCING JUSTICE

COUNTUSIN2020.ORG

# ជំរឿន 101

*មានសំណួរមែនទេ? សូមហៅទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទទាន់ហេតុការណ៍ផ្នែកជំរឿនរបស់យើងតាមលេខ 844-2020-API សម្រាប់ជំនួយគាំទ្រជាភាសាអង់គ្លេស និងភាសាដទៃផ្សេងទៀត។ សូមចូលមើលគេហទំព័រ [www.CountUsIn2020.org/hotline](www.CountUsIn2020.org/hotline) សម្រាប់ព័ត៌មានបន្ថែម។*

រៀងរាល់10ឆ្នាំ រដ្ឋាភិបាលសហរដ្ឋអាមេរិករាប់បញ្ចូលមនុស្សគ្រប់រូបដែលរស់នៅក្នុងសហរដ្ឋ អាមេរិកតាមរយៈការធ្វើជំរឿន។ ជំរឿនគឺជាកម្រងសំណួរខ្លីដែលទាមទារព័ត៌មានមូលដ្ឋាន អំពីគ្រួសាររបស់អ្នក និងសមាជិកដែលរស់នៅក្នុងនោះ។ ការឆ្លើយតបផ្ទាល់របស់អ្នកគឺជា ការសម្ងាត់។

ជំរឿនបានចាប់ផ្តើមនៅក្នុងខែមករា ឆ្នាំ 2020 នៅតំបនដាច់ស្រយាលនៃរដ្ឋអាឡាស្កា ហើយក្រុមគ្រួសារសឹងទាំងអស់នឹងទទួលបានការអញ្ជើញរបស់ពួកគេឲ្យឆ្លើយតបនៅ **ខែមីនា ឆ្នាំ 2020**។ អ្នកត្រូវប្រាកដចិត្តថាអ្នកនឹងត្រូវបានរាប់បញ្ចូលដើម្បីទទួលបានការចែករំលែកធនធាន និងអ្នកតំណាងរបស់អ្នកដោយយុត្តិធម៌!

## ការដែលត្រូវបានរាប់ក្នុងជំរឿនជួយដល់អ្នក និង គ្រួសាររបស់អ្នក។

- ទិន្នន័យពីការធ្វើជំរឿនត្រូវបានយកទៅប្រើប្រាស់ដើម្បីបែងចែកថវិកាជាង **$1.5 លានលានដុល្លារ**នៃការផ្តល់ថវិការបស់រដ្ឋាភិបាល សម្រាប់សេវាកម្ម សំខាន់ៗ ដូចជា សាលារៀន បណ្ណាល័យ ចំណីអាហារ និង សេវាថែទាំសុខភាព។
- ទិន្នន័យពីជំរឿននេះក៏ត្រូវបានប្រើដើម្បីបែងចែកអ្នកតំណាងនយោបាយផងដែរ។ តំបន់របស់អ្នកមានចំនួនប្រជាជនច្រើនប៉ុណ្ណា ចំនួនអ្នកតំណាងរបស់អ្នកក៏មានច្រើនប៉ុណ្ណោះដែរ។

## ការឆ្លើយតបរបស់អ្នកគឺជាការសម្ងាត់។

ការជំរឿនឆ្នាំ 2020 នឹងមិនសួរអំពីស្ថានភាពជាប្រជាពលរដ្ឋ ឬអន្តោប្រវេសន៍ឡើយ។ ការិយាល័យជំរឿនមិនមានសិទ្ធចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកជាមួយភ្នាក់ងាររដ្ឋាភិបាល មន្ត្រីអន្តោប្រវេសន៍ ឬ សាធារណជនណាមួយឡើយ។ ច្បាប់តឹងរឹងអាចការពារចម្លើយរបស់អ្នកពីការចែកចាយបាន។ ការឆ្លើយតបទៅនឹងជំរឿនត្រូវបានប្រើសម្រាប់តែក្នុងគោលបំណងប្រមូលស្ថិតិតែប៉ុណ្ណោះ។

## ការឆ្លើយតបទៅនឹងជំរឿនគឺរហ័ស និង ងាយស្រួល។

- **អ្នកអាចឆ្លើយតបតាមប្រព័ន្ធអ៊ីនធឺណិត។** ការិយាល័យជំរឿននឹងផ្ញើការណែនាំអ្នកនៅ**ពាក់កណ្តាលខែមីនា ឆ្នាំ2020** ។ ចូលទៅកាន់គេហទំព័រជំរឿនផ្លូវការបញ្ចូល ID គ្រួសាររបស់អ្នក ហើយបន្ទាប់មកឆ្លើយនឹងសំនួរ។
- **អ្នកអាចឆ្លើយតបតាមទូរស័ព្ទ។** ទូរស័ព្ទទៅការិយាល័យជំរឿនដើម្បីឆ្លើយតបទៅនឹងជំរឿន ហើយសួរសំណួរផ្សេងៗទាក់ទងនឹងការធ្វើជំរឿន។
- ប្រសិនបើអ្នកមិនឆ្លើយតបទៅនឹងជំរឿនតាមប្រព័ន្ធអ៊ិនធ័រណែត ឬ តាមទូរស័ព្ទ ការិយាល័យជំរឿននឹងផ្ញើ**កម្រងសំណួរជាក្រដាស**ទៅអ្នក។

ប្រសិនបើអ្នកមិនឆ្លើយតបចាប់នៅខែឧសភា ឆ្នាំ2020ទេ បុគ្គលិកជំរឿនអាចចុះមកផ្ទះរបស់អ្នកដើម្បីសាកសួរព័ត៌មានដោយផ្ទាល់។ អ្នកនៅតែអាចឆ្លើយតបតាមប្រព័ន្ធអ៊ីនធឺណិត ឬ ឆ្លើយតបតាមទូរស័ព្ទបានរហូតដល់ខែកក្កដា ឆ្នាំ2020 ។

## ជំនួយខាងភាសាមានជូនសម្រាប់ភាសាមួយចំនួន។

កម្រងសំណួរតាមប្រព័ន្ធអ៊ីនធឺណេត និង ជំនួយតាមទូរស័ព្ទមានសម្រាប់ភាសា អេស្ប៉ាញ ចិន វៀតណាម កូរ៉េ រុស្ស៊ី អារ៉ាប់ តាហ្គាឡុក ប៉ូឡូញ បារាំង ហៃទី អ៊ីរ៉ង់ ព័រទុយហ្គាល់ និង ជប៉ុន។ ការិយាល័យជំរឿនបានបង្កើតសទ្ទានុក្រមភាសា ប័ណ្ណសម្គាល់ភាសា និង មគ្គុទេសក៍ជាភាសាចំនួន 59 ភាសាទៀតមិនមែនជាភាសាអង់គ្លេសដែលអាចរកបាននៅគេហទំព័រ www.2020census.gov/en/languages.html។

*អ្នកអាចស្វែងរកព័ត៌មានបន្ថែមទៀតអំពីជំរឿននៅ www.CountUsIn2020.org/resources។*